## តើខ្ញុំគួររំពឹងអ្វីខ្លះ?

មជ្ឈមណ្ឌលនីតិសម្បទាសម្រាប់ការស្នាក់នៅ (RHCs) ត្រូវបានបញ្ជាក់ថាជាមណ្ឌលថែទាំកម្រិតមធ្យម ដែលផ្ដល់សុខភាពទូលំទូលាយ និងជាលក្ខណៈបុគ្គល និងសេវាស្ដារនីតិសម្បទាដល់អ្នកដែលមានពិការភាពបញ្ញា និងការលូតលាស់ ដើម្បីលើកកម្ពស់ស្ថានភាពមុខងារ និងឯករាជ្យភាពរបស់ពួកគេ ដើម្បីឱ្យពួកគេអាចត្រលប់ទៅកាន់សហគមន៍របស់ពួកគេវិញ។ គោលដៅនៃឱ្យចាកចេញត្រូវបានពិភាក្សាមុនពេលឱ្យចូល និងត្រូវបានផ្អែកលើតម្រូវការគាំទ្រដែលបានកំណត់អត្តសញ្ញាណរបស់អតិថិជនដែលកំពុងតែការពារពួកគេពីការរស់នៅក្នុងបណ្ដាសហគមន៍របស់ពួកគេ។

ខណៈពេលទទួលបានសេវាកម្ម ជណរអីឌ ក្រុមអន្តរវិន័យ (IDT) ធ្វើការជាមួយអតិថិជនដើម្បីអភិវឌ្ឍផែនការនីតិសម្បទាជាបុគ្គល (IHP) ដែលរួមមានការរៀបរាប់លម្អិតពីតម្រូវការ ការគាំទ្រ និងចំណូលចិត្តរបស់អតិថិជនដើម្បីជួយក្នុងការផ្លាស់ប្ដូរទៅបរិយាកាសមានការរឹតបន្តឹងតិចជាង។ អតិថិជន និងតំណាងស្របច្បាប់របស់ពួកគេ គឺជាផ្នែកសំខាន់របស់ IDT។

ប្រធានធនធានសំណុំរឿង DDA របស់អ្នក ក៏ជាសមាជិកក្រុមសំខាន់របស់អ្នកផងដែរ។ ពួកគេនឹងផ្ដល់ការគាំទ្រ និងការសម្របសម្រួលមុនពេល និងអំឡុងពេលដំណើរការចូលនៅ ហើយនឹងបន្តចូលរួមក្នុងអំឡុងពេលការផ្លាស់ប្ដូររបស់អ្នកដើម្បីជួយសម្របសម្រួលសេវាផ្អែកលើសហគមន៍ ជាផ្នែកនៃផែនការឱ្យចាកចេញរបស់អ្នក។



Washington State
Department of Social & Health Services
*Transforming lives*

DSHS 22-1885 CA (3/22) Cambodian



# មជ្ឈមណ្ឌលនីតិសម្បទាសម្រាប់ការស្នាក់នៅ

## មណ្ឌលថែទាំកម្រិតមធ្យម



Washington State
Department of Social & Health Services
*Transforming lives*

## តើសេវាមណ្ឌលថែទាំកម្រិតមធ្យមសម្រាប់អ្នកដែលមានពិការភាពបញ្ញា (ICF/IID) មានអ្វីខ្លះ?

រដ្ឋបាលពិការភាពខាងការលូតលាស់ (DDA) របស់ ឌសិះសិ ដំណើរការ RHC ចំនួនបី (3) ដែលបញ្ជាក់ដោយសហព័ន្ធដើម្បីផ្តល់ការគាំទ្រសុខភាព និងការស្តារនីតិសម្បទាដល់អ្នកដែលមានពិការ
ភាពបញ្ញា និងការលូតលាស់។ វិញ្ញាបនបត្រសហព័ន្ធមានន័យថាមជ្ឈមណ្ឌលសម្រាប់សេវ aMedicare និង Medicaid កំណត់ស្តង់ដារជាក់លាក់ ក្រមបទបញ្ញត្តិសហព័ន្ធ (C.F.R), ដែល RHCs ត្រូវតែបំពេញតាម។

ការឱ្យចូលនៅគឺបណ្តោះអាសន្ន ពីព្រោះគោលបំណងគឺសម្រាប់ឱ្យអតិថិជនទទួលសេវាកម្មនានាក្នុងសហគមន៍នៅពេលដែលពួកគេបានបំពេញគោលដៅនីតិសម្បទារបស់ពួកគេរួច។

សេវា ICF/IID នៅក្នុង Washington ដែលបានផ្តល់ដោយ RHCs ដែលដំណើរការដោយរដ្ឋ ៖ សាលា Fircrest នៅ Shoreline, Lakeland Village នៅ Spokane និងសាលា Rainier នៅ Buckley ។



## តើខ្ញុំចូលប្រើសេវា ICF/IID ដោយរបៀបណា?

ដើម្បីមានសិទ្ធិទទួលបានសេវa ICF/IID បណ្តោះអាសន្ន អតិថិជនត្រូវតែបំពេញសិទ្ធិទទួលបាន ICF/IID និងតម្រូវការសិទ្ធិទទួលបាន RHC ដូចបានចែងនៅក្នុង DDA គោលការណ៍ 17.02។

**សិទ្ធិទទួលបានសេវា ICF/IID –**

- សិទ្ធិទទួលបាន DDA ដែលបានកំណត់ក្រោមជំពូក 388-823 WAC;
- សិទ្ធិទទួលបាន edicaid ដែលបានកំណត់ក្រោមមាត្រា 182 WAC;
- មានអាយុ 21 ឆ្នាំឡើង បើសិនបើអាយុ 16-20 ឆ្នាំ សេវាសហគមន៍ដែលបំពេញតាមសេចក្តីត្រូវការរបស់អ្នកបានត្រឹមត្រូវ គឺមិនមានទេ; និង
- បំពេញកម្រិតថែទាំ ICF/IID ដូចបានកំណត់ដោយការវាយតម្លៃ DDA

**សិទ្ធិទទួលបាន RHC –**

- មានសេចក្តីត្រូវការសុខភាព និងសុខុមាលភាពដែលបានកំណត់អត្តសញ្ញាណដែលបច្ចុប្បន្នបានបំពេញដោយសេវានីតិសម្បទាសម្រាប់ការស្នាក់នៅ
- មិនតម្រូវឱ្យមានការព្យាបាលអ្នកជំងឺស្នាក់នៅមន្ទីរពេទ្យចេញវេជ្ជបញ្ជាដោយអ្នកជំនាញព្យាបាលរបស់អតិថិជនទេ
- មិនជាប់ឃុំឃាំងពីបទឧក្រិដ្ឋ ការឃុំខ្លួន និងដំណើរការបណ្តឹងរដ្ឋប្បវេណីត្រូវបានច្រានចោល និង
- ការវាយតម្លៃបឋមដោយបុគ្គលិក RHC កំណត់ថា អតិថិជនបំពេញបានតាមតម្រូវការការព្យាបាលសកម្ម

អ្នកអាចទាក់ទងប្រធានធនធានសំណុំរឿងសេវាវាល DDA របស់អ្នក ប្រសិនបើអ្នកមានសំណួរបន្ថែម ឬដើម្បីស្នើសុំសេវា ICF/IID ។



## តើការព្យាបាលសកម្មគឺជាអ្វី?

ការព្យាបាលសកម្មដូចបានកំណត់នៅក្នុង 42 C.F.R. 483.440(a)(1)(2), មានន័យថាកម្មវិធីកំពុងបន្ត ដែលរួមមានការអនុវត្តយ៉ាងស៊ីសង្វាក់គ្នានៃកម្មវិធីបណ្តុះបណ្តាលឯកទេស និងទូទៅ ការព្យាបាល សេវាសុខភាព និងសេវាដែលទាក់ទងដែលដឹកនាំឆ្ពោះទៅ ៖

- ការទទួលបានអាកប្បកិរិយាដែលចាំបាច់សម្រាប់អតិថិជនដើម្បីបំពេញមុខងារដោយការសម្រេចចិត្តខ្លួនឯង និងឯករាជ្យតាមតែអាចធ្វើបាន និង
- ទប់ស្កាត់ និងបន្ថយចលនាថយ ឬការបាត់បង់ស្ថានភាពមុខងារល្អប្រសើរ។

ការព្យាបាលសកម្មមិនរួមបញ្ចូលសេវាក្នុងការរក្សាឯករាជ្យភាពអតិថិជនជាទូទៅដែលអាចធ្វើការដោយមានការត្រួតពិនិត្យតិចតួច ឬនៅក្នុងអវត្តមាននៃកម្មវិធីការព្យាបាលសកម្មបន្ត។

មុនពេលឱ្យចូលនៅ ផ្នែកនៃការវាយតម្លៃបឋម RHC គឺត្រូវកំណត់ថាអតិថិជនយល់ព្រមចូលរួម មានសេចក្តីត្រូវការសម្រាប់ និងទំនងជាទទួលប្រយោជន៍ពីកម្មវិធីការព្យាបាលសកម្មបន្ត។

## តើការឱ្យចូលនៅបណ្តោះអាសន្នមានន័យដូចម្តេច?

សេវា ICF/IID គឺបណ្តោះអាសន្ន។ អតិថិជនដែលមានសិទ្ធិទទួលអាចនឹងទទួលបានសេវា ICF/IID រហូតដល់លក្ខណៈវិនិច្ឆ័យនៃការឱ្យចាកចេញរបស់ពួកគេត្រូវបានបំពេញ ឬពួកគេលែងទទួលអត្ថប្រយោជន៍ពី ឬលែងមានឆន្ទៈចូលរួមក្នុងការព្យាបាលសកម្មទៀតហើយ។ ការឱ្យចូលជាអចិន្ត្រៃយ៍ ឬរយៈពេលវែងនៅ ICF/IID គឺមិនមានទេ។

បទបញ្ញត្តិសហព័ន្ធទាមទារឱ្យបុគ្គលម្នាក់ៗចាកចេញពី ICF នៅពេល ៖

1. មណ្ឌលមិនអាចបំពេញតាមសេចក្តីត្រូវការរបស់អតិថិជន
2. អតិថិជនលែងទាមទារការព្យាបាលក្នុង ICF ទៀតហើយ
3. អតិថិជនជ្រើសរើសរស់នៅកន្លែងផ្សេង ឬ
4. សេចក្តីសម្រេចចុងក្រោយត្រូវបានធ្វើឡើងថាកម្រិតផ្សេងនៃសេវាកម្ម ឬស្ថានភាពរស់នៅនឹងមិនមានអត្ថប្រយោជន៍ដល់អតិថិជនឡើយ